ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៩ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈបញ្ជាការឯកភាពនៃការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៩ អនក្រ.បក ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ៣១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៧២ សសរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២៣៥ សសរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារជាតុញៀននិងសារជាតុគីមីផ្សំ
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**ប្រការ១ .-**

គ្រូវបានបង្កើតគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រធាន

២- ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន

៣- ឯកឧត្តម **ញ៉ុំ សុខា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានប្រចាំការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

៤- ឯកឧត្តម **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

៥- ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន សមាជិក

៦- ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៧- លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិកា

៨- លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី សមាជិកា

៩- ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

១០- ឯកឧត្តម **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា សមាជិក

១១- ឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក

១២- ឯកឧត្តម **កេត សោផាន់** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣- ឯកឧត្តម **ប្រាក់ សំអឿន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៤- ឯកឧត្តម **ភង សុខន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៥- ឯកឧត្តមនាយឧត្តមសេនីយ៍ **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១៦- ឯកឧត្តម **ស្តើង សុខុម** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៧- ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ សមាជិក

១៨- ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៩- ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** អគ្គលេខាធិការនៃអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក។

អនុប្រធាននិងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ២ .-**

គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់មានតួនាទីនិងភារកិច្ចដឹកនាំបញ្ជានិងចាត់តាំង អនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ របស់រាជរដ្ឋាភិបាល។

**ប្រការ៣ .-**

គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់មានគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ លេខាធិការដ្ឋានចំនួន១(មួយ) និងគណៈកម្មការចំនួន៥(ប្រាំ) ជាសេនាធិការ។

គណៈកម្មការចំនួន៥(ប្រាំ) មានដូចខាងក្រោម៖

១- គណៈកម្មការទទួលបន្ទុកផ្សព្វផ្សាយអប់រំ។

២- គណៈកម្មការទទួលបន្ទុកអនុវត្តវិធានការរដ្ឋបាល។

៣- គណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែន និងតាមច្រកទ្វារព្រំដែន។

៤- គណៈកម្មការទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិ។

៥- គណៈកម្មការផ្គត់ផ្គង់។

**ប្រការ៤ .-**

គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវអនុវត្តភារកិច្ចតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ៤៩ អនក្រ.បក ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

**ប្រការ៥ .-**

ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ ត្រូវអនុវត្តភារកិច្ចតាមបទប្បញ្ញត្តិនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២៣៥ សសរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ និងអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

**ប្រការ៦ .-**

លេខាធិការដ្ឋានមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** | អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២- ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** | អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តមឧត្តមសេនីយ៍ឯក **ផាត សុផានិត** | អគ្គលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឧត្តមសេនីយ៍ឯក **ឆាយ គឹមខឿន** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ៥- | ឧត្តមសេនីយ៍ឯក **ឡោ សុឡេខ** | អគ្គស្នងការរងនិងជាស្នងការនៃ<br>ស្នងការដ្ឋានហិរញ្ញកិច្ចនិងភស្តុភារ | សមាជិក |
| ៦- | ឧត្តមសេនីយ៍ឯក **ម៉ុនប៉ា ម៉ារីលុច** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧- | ឯកឧត្តម **នុប សុធនវិសុទ្ធ** | ព្រះរាជអាជ្ញានិងជាអគ្គនាយករងនៃអគ្គនាយកដ្ឋាន<br>កិច្ចការអយ្យការនិងព្រហ្មទណ្ឌក្រសួងយុត្តិធម៌ | សមាជិក |
| ៨- | ឧត្តមសេនីយ៍ឯក **នាក់ យុទ្ធា** | អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ. | សមាជិក |
| ៩- | ឧត្តមសេនីយ៍ឯក **ណុប នរិន្ទ** | អគ្គនាយករងអន្តោប្រវេសន៍ | សមាជិក |
| ១០- | ឧត្តមសេនីយ៍ឯក **ហុខ វិណុល** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១១- | លោកវេជ្ជបណ្ឌិត **លន់ ច័ន្ទរស្មី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស<br>សុខាភិបាលក្រសួងសុខាភិបាល | សមាជិក |
| ១២- | លោកស្រី **នខ រ័ត្នថា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានព័ត៌មាន<br>និងសោតទស្សន៍ក្រសួងព័ត៌មាន | សមាជិកា |
| ១៣- | លោក **ឡោ សុវិជ្ជា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍<br>និងសហប្រតិបត្តិការអន្តរជាតិក្រសួងទេសចរណ៍ | សមាជិក |
| ១៤- | លោក **ហ៊ីន ចាន់រិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល<br>និងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥- | លោក **សួខ សទ្ធាវុទ្ធី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦- | លោក **ទិត វ៉ាល់ដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានស្ត្រីនីតិសម្បទា<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៧- | លោក **ធួក ដារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៨- | ឧត្តមអគ្គានុរក្ស.១ **លឹម សុខា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ | សមាជិក |
| ១៩- | លោក **ដោក ណារ៉ុន** | អគ្គនាយករងក្រសួងធម្មការនិងសាសនា | សមាជិក |
| ២០- | ឧត្តមសេនីយ៍ឯក **ឈឹម សិទ្ធិបុណ្យរិទ្ធ** | អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ. | សមាជិក |
| ២១- | ឧត្តមសេនីយ៍ឯក **ជុន ថាវៀត** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ<br>នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. | សមាជិក |
| ២២- | ឧត្តមសេនីយ៍ឯក **ឃឹម សារ៉ាត់** | នាយកមន្ទីរប្រឆាំងគ្រឿងញៀន<br>នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២៣- | ឧត្តមសេនីយ៍ទោ **អ៊ុំ សត្យា** | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ<br>នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២៤- | ឧត្តមសេនីយ៍ទោ **ចាន់ សម្បត្តិ** | ប្រធាននាយកដ្ឋានសរុប ផែនការ<br>នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២៥- | ឧត្តមសេនីយ៍ទោ **សួន ឡឿន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ<br>នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. | សមាជិក។ |

លេខាធិការដ្ឋាននេះមានភារកិច្ចដូចតទៅ៖

- តាមដាននិងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងការអនុវត្តផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ប្រមូលនិងរៀបចំរបាយការណ៍បូកសរុបបម្រើឱ្យកិច្ចប្រជុំដឹកនាំត្រួតពិនិត្យលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់
- សម្របសម្រួល ផ្សព្វផ្សាយបទបញ្ជា គោលការណ៍របស់ថ្នាក់ដឹកនាំ ជូនដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ព្រមទាំងរៀបចំកម្មវិធីប្រជុំនានា តាមការបញ្ជាដឹកនាំរបស់ប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់
- លើកគម្រោងថវិកាប្រាក់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំជូនដល់អង្គភាព និងមន្ត្រីអនុវត្តច្បាប់ដែលមានស្នាដៃក្នុងការបង្ក្រាប ចាប់យកសារធាតុញៀនដែលមានភាពសុទ្ធចាប់ពី១០០ក្រាមឡើងទៅ
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

**ប្រការ៧ .–**

គណៈកម្មការទទួលបន្ទុកផ្សព្វផ្សាយអប់រំមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **នេត្រ ភក្ត្រា** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | ប្រធាន |
| ២- ឯកឧត្តម **ហេង សួរ** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- លោកជំទាវ **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | អនុប្រធាន |
| ៥- ឯកឧត្តម **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| ៦- ឯកឧត្តម **ចាយ បូរិន** | រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា | អនុប្រធាន |
| ៧- ឯកឧត្តម **សុខ សូកេន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៨- លោកជំទាវ **គីម សេដ្ឋានី** | រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធានអចិន្ត្រៃយ៍ |
| ៩- ឯកឧត្តម **ឈី ហ៊ុង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០- ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក |
| ១១- ឧត្តមសេនីយ៍ឯក **ថោង សុគន្ធា** | អគ្គលេខាធិការរង អ.ជ.ប.គ.ញ. | សមាជិក |
| ១២- លោក **សំរិត ជេដ្ឋាភិរម្យ** | អគ្គលេខាធិការរង អ.ជ.ប.គ.ញ. | សមាជិក |
| ១៣- ឧត្តមសេនីយ៍ឯក **លឹម គុងហួត** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយ អប់រំ និងទំនាក់ទំនងសាធារណៈនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. | សមាជិក |
| ១៤- លោក **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀននៃក្រសួងសុខាភិបាល | សមាជិក។ |

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ដាក់ចេញនូវវិធានការណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត រោងចក្រ សហគ្រាស ក្រុមហ៊ុនដឹកជញ្ជូន គោលដៅទេសចរណ៍ គ្រឹះស្ថានសិក្សា និងសហគមន៍នានាជាដើម ដើម្បីកំណត់គោលដៅងាយកើតមានបទល្មើសគ្រឿងញៀន និងមុខសញ្ញាងាយរងគ្រោះដោយសារឥទ្ធិពលនៃគ្រឿងញៀននៅតាមភូមិសាស្ត្រនីមួយៗ ព្រមទាំងណែនាំអំពី

ការរៀបចំផែនការសកម្មភាព ដើម្បីធ្វើការផ្សព្វផ្សាយអប់រំ និងមានកម្មវិធីត្រួតពិនិត្យដើម្បីធ្វើឱ្យវិធានការនេះមានប្រសិទ្ធភាព

- រៀបចំកម្មវិធីបំផុសចលនាឱ្យមានសកម្មភាពចូលរួមពីគ្រប់សមាសភាពនៃសង្គម ដើម្បីផ្សព្វផ្សាយអប់រំ អំពីច្បាប់និងផលប៉ះពាល់នៃគ្រឿងញៀន តាមរយៈវេទិកាផ្សព្វផ្សាយគោលនយោបាយ **ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព** វេទិកាសិល្បៈ ការប្រគុំតន្ត្រី កម្មវិធីកីឡា ភាពយន្ត គំនូរ កំណាព្យ ពាក្យស្លោក ខិត្តប័ណ្ណ ផ្ទាំងរូបភាព សារទូរស័ព្ទ វេទិកា ឬកម្មវិធីសាសនា និងសកម្មភាពផ្សេងៗទៀត ជាពិសេសសកម្មភាពផ្សព្វផ្សាយអប់រំដោយផ្ទាល់ដល់ខ្នងផ្ទះប្រជាពលរដ្ឋ
- រៀបចំបញ្ចូលនៅក្នុងកម្មវិធីសិក្សាអប់រំអំពីច្បាប់ ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនដល់សិស្ស និស្សិត ព្រមទាំងរៀបចំវេទិកាផ្សព្វផ្សាយជាក់ស្តែងនៅតាមគ្រឹះស្ថានសិក្សាឱ្យបានទូលំទូលាយ
- បំផុសចលនាបុគ្គលដែលស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ឱ្យទៅទទួលការព្យាបាលនិងស្តារនីតិសម្បទានៅតាមសហគមន៍ និងមណ្ឌលបណ្តោះអាសន្ននានាទាំងរដ្ឋនិងឯកជន
- រៀបចំក្រុមការងារវេទិកាគុម្ពល ដើម្បីផ្សព្វផ្សាយ អប់រំ អំពីច្បាប់និងផលប៉ះពាល់នៃគ្រឿងញៀន ព្រមទាំងអំពាវនាវដល់ប្រជាពលរដ្ឋនៅគ្រប់មជ្ឈដ្ឋាន ឱ្យចូលរួមក្នុងចលនាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមទិសស្លោក **៣កុំ ១រាយការណ៍**នៅតាមកម្មវិធីទូរទស្សន៍ វិទ្យុ បណ្តាញផ្សាយព័ត៌មានសង្គម ឱ្យបានជាប់ជាប្រចាំ
- រៀបចំកម្មវិធី និងខ្លឹមសារ ព្រមទាំងបើកវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមគ្រូបង្គោលឱ្យបានទូលំទូលាយសំដៅពង្រឹងនិងពង្រីកសកម្មភាពផ្សព្វផ្សាយអប់រំអំពីច្បាប់ និងផលប៉ះពាល់នៃគ្រឿងញៀនឱ្យសស្រាក់សស្រាំគ្មៀវក្លា
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

**ប្រការ៨ .-**

គណៈកម្មការទទួលបន្ទុកអនុវត្តវិធានការរដ្ឋបាលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ប្រាក់ សំអឿន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- | ឯកឧត្តម **ឆែម សាឆុន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- | ឯកឧត្តម **ភាទើ មហាំម៉ាត់ណោសស្រ៊ី** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- | ឯកឧត្តម **គង់ វិមាន** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៥- | ឯកឧត្តម **សាត សាមី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៦- | លោកជំទាវបណ្ឌិត **ស៊ឿ សុជាតា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ៧- | ឯកឧត្តមឧត្តមអគ្គានុរក្ស.១ **ឈន សារណាត** | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ | សមាជិក |
| ៨- | ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក |
| ៩- | ឧត្តមសេនីយ៍ឯក **ព្រុំ សន្ធរ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១០- | ឧត្តមសេនីយ៍ឯក **ហុខ ចិណ្ណាល** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១១- | ឯកឧត្តម **ព្រុំ ធី** | អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ | សមាជិក |
| ១២- | ឧត្តមសេនីយ៍ទោ **ឡេខ ប៊ុនណា** | អគ្គលេខាធិការរងនៃ អ.ជ.ប.គ.៣. | សមាជិក |
| ១៣- | ឧត្តមសេនីយ៍ទោ **ឡាយ សំអឿន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. | សមាជិក។ |

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ជំរឿងបញ្ជីនិងក្តាប់ឱ្យបាននូវគោលដៅដែលងាយរងផលប៉ះពាល់ដោយសារអំពើជួញដូរ ប្រើប្រាស់ រក្សាទុក កែច្នៃផលិតគ្រឿងញៀនខុសច្បាប់ រួមទាំងការរក្សាទុកសារធាតុគីមីផ្សំ ហើយត្រូវអញ្ជើញម្ចាស់ទីតាំងទាំងនោះមកធ្វើការពន្យល់ណែនាំឱ្យយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានហ្មត់ចត់ ព្រមទាំងធ្វើកិច្ចសន្យាសហការបង្ការទប់ស្កាត់មិនឱ្យមានបទល្មើសគ្រឿងញៀននៅក្នុងទីតាំងរបស់ខ្លួន
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសាធារណៈ រោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្ម និងវិស័យឯកជន សំដៅរួមសហការក្នុងការបង្ការ ទប់ស្កាត់ ព្រមទាំងអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ក្នុងករណីរកឃើញមានបទល្មើសគ្រឿងញៀន
- ចាត់វិធានការហ្មត់ចត់ ដាច់ខាត ក្នុងការបិទ ដកហូតច្បាប់អនុញ្ញាតធ្វើអាជីវកម្មមួយរយៈ ឬជាស្ថាពរ ចំពោះទីតាំងអាជីវកម្មទាំងឡាយណាដែលសមត្ថកិច្ចរកឃើញថា មានពាក់ព័ន្ធបទល្មើសគ្រឿងញៀន
- ក្នុងករណីមានព័ត៌មានតម្រុយច្បាស់លាស់ ត្រូវសហការជាមួយសមត្ថកិច្ចអនុវត្តច្បាប់ បើកប្រតិបត្តិការត្រួតពិនិត្យរដ្ឋបាល ស្របជាមួយប្រតិបត្តិការអនុវត្តច្បាប់
- យកចិត្តទុកដាក់រៀបចំក្រុមការងារដើម្បីចុះត្រួតពិនិត្យ និងពង្រឹងការងារគ្រប់គ្រងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែ ដោយទប់ស្កាត់ឱ្យបាននូវការលួចនាំចូល ការប្រើប្រាស់ និងការជួញដូរនូវសារធាតុញៀន និង/ឬមានទំនាក់ទំនងពីក្នុងពន្ធនាគារមកក្រៅ ពីមជ្ឈដ្ឋានខាងក្រៅមកក្នុងពន្ធនាគារពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសគ្រឿងញៀន
- ពង្រឹងវិន័យ ក្រមសីលធម៌ មនសិការវិជ្ជាជីវៈរបស់អនុរក្សពន្ធនាគារ ព្រមទាំងលើកវិធានការគ្រប់គ្រងដោយឡែកចំពោះទណ្ឌិតឬពិរុទ្ធជនដែលពាក់ព័ន្ធគ្រឿងញៀន ឱ្យបានម៉ឺងម៉ាត់និងហ្មត់ចត់
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

**ប្រការ៩ .-**

គណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែន និងតាមច្រកទ្វារព្រំដែន មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **គង សុខន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **ព្រហ្ម សិទ្ធត្រា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- ឯកឧត្តម **កែ គី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៤- ឯកឧត្តម **ខាយ ឃុនហេង** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៥- ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** | អគ្គលេខាធិការនៃ អ.ជ.ប.គ.ញ. | អនុប្រធាន |
| ៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ វាសនា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធាន |
| ៧- ឧត្តមសេនីយ៍ឯក **ម៉ិនប៉ា ម៉ារីលុច** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៨- ឯកឧត្តម **ភើត សុទ្ធារ៉ា** | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៩- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី | | សមាជិក |
| ១០- នាយឧត្តមសេនីយ៍ **ខេង សុមេធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១១- ឧត្តមសេនីយ៍ឯក **គឹម ឃន** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |

១២- ឧត្តមសេនីយ៍ឯក **ហុង វិណុល** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៣- ឧត្តមសេនីយ៍ទោ **ស៊ិន សុខា** នាយកទីចាត់ការការងារព្រំដែន
នៃកងយោធពលខេមរភូមិន្ទ សមាជិក
១៤- ឧត្តមសេនីយ៍ឯក **ពៅ ហេង** មេបញ្ជាការរងកងទ័ពជើងគោក
និងជាមេបញ្ជាការយោធភូមិភាគ៤ សមាជិក
១៥- ឧត្តមសេនីយ៍ទោ **លី សូរ៉ារិទ្ធ** មេបញ្ជាការយោធភូមិភាគ១ សមាជិក
១៦- ឧត្តមសេនីយ៍ឯក **ឃឹម សារ៉ាត់** នាយកមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក
១៧- ឧត្តមសេនីយ៍ទោ **ឃន តារាសម្បត្តិ** ប្រធាននាយកដ្ឋានអនុវត្តច្បាប់
នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. សមាជិក
១៨- ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី សមាជិក
១៩- មេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី សមាជិក។

គណៈកម្មការនេះមានភារកិច្ចដឹកនាំការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែននិងតាមច្រកទ្វារព្រំដែន និងទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

គណៈកម្មការនេះមានអនុគណៈកម្មការចំនួន៣(បី) ជាសេនាធិការដូចខាងក្រោម៖

**ក.** អនុគណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែន ភាគឦសាន មានសមាសភាពដូចខាងក្រោម៖

១- ឧត្តមសេនីយ៍ឯក **ម៉ិនប៉ា ម៉ារីលុច** អគ្គស្នងការរងនគរបាលជាតិ ប្រធាន
២- ឯកឧត្តម **នុប សុធនវិសុទ្ធ** ព្រះរាជអាជ្ញានិងជាអគ្គនាយករងនៃអគ្គនាយកដ្ឋាន
កិច្ចការអយ្យការនិងព្រហ្មទណ្ឌក្រសួងយុត្តិធម៌ អនុប្រធាន
៣- នាយឧត្តមសេនីយ៍ **ឃុន សំបូរ** អគ្គនាយករងអន្តោប្រវេសន៍ អនុប្រធាន
៤- ឧត្តមសេនីយ៍ឯក **គឹម ឃន** អគ្គស្នងការរងនគរបាលជាតិ អនុប្រធាន
៥- ឧត្តមសេនីយ៍ឯក **គឿន សុភត្រា** អគ្គនាយករងអន្តោប្រវេសន៍ អនុប្រធាន
៦- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី សមាជិក
៧- ឧត្តមសេនីយ៍ទោ **ស៊ិន សុខា** នាយកទីចាត់ការការងារព្រំដែន
នៃកងយោធពលខេមរភូមិន្ទ សមាជិក
៨- ឧត្តមសេនីយ៍ឯក **ពៅ ហេង** មេបញ្ជាការរងកងទ័ពជើងគោក
និងជាមេបញ្ជាការយោធភូមិភាគ៤ សមាជិក
៩- ឧត្តមសេនីយ៍ទោ **លី សូរ៉ារិទ្ធ** មេបញ្ជាការយោធភូមិភាគ១ សមាជិក
១០- ឧត្តមសេនីយ៍ឯក **ឃឹម សារ៉ាត់** នាយកមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក
១១- ឧត្តមសេនីយ៍ទោ **ឃន តារាសម្បត្តិ** ប្រធាននាយកដ្ឋានអនុវត្តច្បាប់
នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. សមាជិក
១២- ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី សមាជិក
១៣- មេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី សមាជិក។

អនុគណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ប្រមូលព័ត៌មានដើម្បីធ្វើការវិភាគនិងវាយតម្លៃអំពីឧបាយកល បែបផែនសកម្មភាពរបស់ក្រុមឧក្រិដ្ឋជន និងផ្លូវចរាចរណ៍ដឹកជញ្ជូនគ្រឿងញៀនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ សំដៅដាក់ចេញនូវផែនការ វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបការហូរចូលគ្រឿងញៀន និងសារធាតុគីមីផ្សំគ្រប់ប្រភេទមកក្នុងប្រទេស
- ចាត់វិធានការដឹកនាំការងារស្រាវជ្រាវ ដំឡើងបញ្ជី ដើម្បីគ្រប់គ្រងមុខសញ្ញាសង្ស័យដែលអាចមានការពាក់ព័ន្ធនឹងគ្រឿងញៀនខុសច្បាប់តាមបណ្តោយព្រំដែនកម្ពុជា-ឡាវ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពិសេសបណ្តាខេត្តជាប់ព្រំដែនកម្ពុជា និងការិយាល័យទំនាក់ទំនងព្រំដែន ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនឱ្យមានប្រសិទ្ធភាព
- ជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ឱ្យអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងវិធានការនានាដែលរាជរដ្ឋាភិបាលនិងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានដាក់ចេញ ក្នុងនោះត្រូវយកចិត្តទុកដាក់ជំរុញការរៀបចំ **ភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀននៅតាមព្រំដែន**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែននិងតាមច្រកទ្វារព្រំដែន។

**ខ.** អនុគណៈកម្មការទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមច្រកទ្វារព្រំដែនមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ ផាសនា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | ប្រធាន |
| ២- ឯកឧត្តម **ផាន អូន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- នាយឧត្តមសេនីយ៍ **ឃុន សំបូរ** | អគ្គនាយករងអន្តោប្រវេសន៍ | អនុប្រធាន |
| ៤- ឧត្តមសេនីយ៍ឯក **អ៊ី សុខឃី** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៥- ឧត្តមសេនីយ៍ឯក **គឿន សុភក្ត្រា** | អគ្គនាយករងអន្តោប្រវេសន៍ | អនុប្រធាន |
| ៦- ឯកឧត្តម **ហ៊ី ធាវី** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ | អនុប្រធាន |
| ៧- ឯកឧត្តម **លូ គីមឈន់** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ | អនុប្រធាន |
| ៨- ឯកឧត្តម **ឈួន ច័ន្ទ** | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | អនុប្រធាន |
| ៩- លោក **ហ៊ីង ពុទ្ធិរិទ្ធ** | ប្រធាននាយកដ្ឋានអាកាសយានដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ១០- ឯកឧត្តម **ម៉ក់ ស៊ីដេត** | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ | សមាជិក |
| ១១- ឯកឧត្តម **ច័ន្ទ ណូរ៉ាក់** | នាយកអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ | សមាជិក |
| ១២- ឯកឧត្តម **ប៊ុន រដ្ឋា** | នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ | សមាជិក |
| ១៣- ឯកឧត្តម **សៅ ចន្ថ្សនា** | នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិក |

១៤- ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក
១៥- ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី សមាជិក
១៦- ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន សមាជិក
១៧- ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងបណ្តារាជធានី ខេត្ត ដែលពាក់ព័ន្ធ សមាជិក
១៨- ឧត្តមសេនីយ៍ឯក **ទូច ពលៈ** ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹក សមាជិក
១៩- ឧត្តមសេនីយ៍ឯក **ឆូ សារឿន** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន សមាជិក
២០- ឧត្តមសេនីយ៍ទោ **អ៊ុយ វ៉ាត់** ប្រធាននាយកដ្ឋានត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សមាជិក
២១- ឧត្តមសេនីយ៍ទោ **សារី បុត្រសត្យា** នាយករងមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក
២២- ឧត្តមសេនីយ៍ទោ **ភៅ ម៉ូមុនី** អនុប្រធាននាយដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សមាជិក
២៣- លោក **អ៊ឹង ជាវ៉េង** អនុប្រធានសាខាគយនិងរដ្ឋាករាជធានីភ្នំពេញ សមាជិក។

អនុគណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ប្រមូលព័ត៌មានដើម្បីធ្វើការវិភាគនិងវាយតម្លៃអំពីឧបាយកល បែបផែនសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនសំដៅដាក់ចេញនូវផែនការ វិធានការបង្ការ ទប់ស្កាត់ ការចរាចរគ្រឿងញៀន និងសារធាតុគីមីផ្សំគ្រប់ប្រភេទឆ្លងកាត់អាកាសយានដ្ឋានអន្តរជាតិ កំពង់ផែអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម និងលំហសមុទ្រ
- សហការជាមួយអង្គការអន្តរជាតិនិងភ្នាក់ងារអនុវត្តច្បាប់នៃបណ្តាប្រទេសជាមិត្ត ដើម្បីផ្លាស់ប្តូរព័ត៌មាន និងសហប្រតិបត្តិការក្នុងការស្រាវជ្រាវ បង្ក្រាបមុខសញ្ញាពាក់ព័ន្ធការចរាចរគ្រឿងញៀនខុសច្បាប់ ឆ្លងកាត់ច្រកទ្វារព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម
- ម្ចាស់ការស៊ើបអង្កេតនិងបង្ក្រាបបទល្មើសគ្រឿងញៀនតាមច្រកទ្វារព្រំដែន
- ពង្រឹងកិច្ចសហការជាមួយបណ្តាខេត្តជាប់ព្រំដែននិងការិយាល័យទំនាក់ទំនងព្រំដែន ដោយត្រូវមានការត្រួតពិនិត្យជាក់ស្តែង និងលើកកម្ពស់សមត្ថភាពរបស់មន្ត្រី ក៏ដូចជាការគាំទ្រជំរុញសកម្មភាពឱ្យដំណើរការប្រកបដោយនិរន្តរភាព
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែន និងតាមច្រកទ្វារព្រំដែន។

**គ.** អនុគណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបញ្ញើប្រៃសណីយ៍មានសមាសភាពដូចខាងក្រោម៖

១- ឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិ ប្រធាន
២- ឯកឧត្តម **ហ្វូត ចាន់យ៉ារ៉េត** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អនុប្រធាន
៣- ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ អនុប្រធាន
៤- លោក **ស៊ីម ធី** អគ្គនាយករងប្រៃសណីយ៍កម្ពុជា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អនុប្រធាន
៥- ឧត្តមសេនីយ៍ឯក **សម វណ្ណាធីរៈ** ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង សមាជិក

៦- ឧត្តមសេនីយ៍ទោ **សាន សុទ្ធី** នាយករងមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក
៧- ឧត្តមសេនីយ៍ត្រី **គា សុហ៊ាង** អនុប្រធាននាយដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សមាជិក
៨- លោកស្រី **ម៉ុន្នី សុជាតា** ប្រធានសាខាគយនិងរដ្ឋាករ ប្រៃសណីយ៍ សមាជិកា។

អនុគណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ប្រមូលព័ត៌មានដើម្បីធ្វើការវិភាគនិងវាយតម្លៃអំពីឧបាយកល បែបផែនសកម្មភាពរបស់ក្រុមឧក្រិដ្ឋជន សំដៅដាក់ចេញនូវផែនការ វិធានការបង្ការ ទប់ស្កាត់ ការចរាចរឆ្លងកាត់គ្រឿងញៀននិងសារធាតុគីមីផ្សំគ្រប់ប្រភេទតាមបញ្ញើប្រៃសណីយ៍
- សហការជាមួយអង្គការអន្តរជាតិនិងភ្នាក់ងារអនុវត្តច្បាប់នៃបណ្តាប្រទេសជាមិត្ត ដើម្បីផ្លាស់ប្តូរព័ត៌មាន និងមានវិធានការស្រាវជ្រាវបង្ក្រាបមុខសញ្ញាពាក់ព័ន្ធការចរាចរគ្រឿងញៀនខុសច្បាប់តាមបញ្ញើប្រៃសណីយ៍
- ម្ចាស់ការស៊ើបអង្កេតនិងបង្ក្រាបបទល្មើសគ្រឿងញៀនតាមបញ្ញើប្រៃសណីយ៍
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែន និងតាមច្រកទ្វារព្រំដែន។

**ប្រការ១០ .-**

ក្រៅពីភារកិច្ចរបស់គណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបណ្តាខេត្តជាប់ព្រំដែន និងតាមច្រកទ្វារព្រំដែនដែលមានអនុគណៈកម្មការទាំង៣ ជាសេនាធិការដូចមានចែងក្នុងប្រការ៩ ការបង្ក្រាបបទល្មើសគ្រឿងញៀនក្រៅភូមិសាស្ត្រច្រកទ្វារព្រំដែន គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចនិងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ១១ .-**

គណៈកម្មការទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **កែត សោផាន់** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
២- ឯកឧត្តម **ប៉ោ គត្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៣- លោកជំទាវ **ឃិនទៀង ពុទ្ធិរស្មី** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
៤- ឯកឧត្តម **សន ច័ន្ទរិទ្ធី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **ផាត សុផានិត** អគ្គលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៦- ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលខេត្តជាប់ព្រំដែន សមាជិក
៧- ឧត្តមសេនីយ៍ឯក **នាក់ យុទ្ធា** អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ. សមាជិក
៨- ឧត្តមសេនីយ៍ឯក **ឡុង ហាចាណា** អគ្គនាយករងអន្តោប្រវេសន៍ សមាជិក
៩- ឧត្តមសេនីយ៍ឯក **សិទ្ធ ប៊ុនធី** អនុប្រធានសេនាធិការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១០- ឧត្តមសេនីយ៍ត្រី **អ៊ុយ សមផល្លារិទ្ធិ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សមាជិក
១១- ឧត្តមសេនីយ៍ត្រី **យូ បូរិន** នាយការិយាល័យនគរបាលអន្តរជាតិ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១២- វរសេនីយ៍ឯក **ម៉ាក់ សេរីវឌ្ឍនៈ** នាយករងមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក។

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ពង្រឹងនិងពង្រីកសកម្មភាពកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានជាមួយដៃគូទ្វេភាគី និងពហុភាគី ដែលមានស្រាប់ទាំងក្នុងនិងក្រៅតំបន់ ព្រមទាំងខិតខំបើកទូលាយនូវទំនាក់ទំនងសហប្រតិបត្តិការជាមួយស្ថាប័នត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិនានា ដើម្បីក្តាប់ជាប់អំពីសភាពការណ៍ និន្នាការតាមដំណាក់កាលនីមួយៗ ក្តាប់ខ្សែរយៈ និងបែបផែនសកម្មភាពរបស់ពួកឧក្រិដ្ឋជនគ្រឿងញៀន សំដៅមានវិធានការម្ចាស់ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលា
- យកចិត្តទុកដាក់សហប្រតិបត្តិការថ្នាក់ជំនាញក្នុងការអនុវត្តការជួយគ្នាទៅវិញទៅមកលើវិស័យយុត្តិធម៌
- បើកទូលាយកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានជំនាញជាមួយស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសនានា ជាពិសេសបណ្តាប្រទេសដែលជាប្រភពផលិតនិងនាំចូលគ្រឿងញៀនឆ្លងកាត់កម្ពុជា ដើម្បីមានវិធានការក្នុងការបង្ក្រាបអង្គការចាត់តាំង ឬបណ្តាញជួញដូរគ្រឿងញៀនជាអន្តរជាតិឱ្យដល់ឫសគល់
- ពង្រឹងកិច្ចសហការអន្តរជាតិក្នុងការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារស៊ើបអង្កេតការសម្អាតប្រាក់ពាក់ព័ន្ធបទល្មើសគ្រឿងញៀន
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

**ប្រការ១២ .-**

គណៈកម្មការផ្គត់ផ្គង់មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ស្តើង សុខុម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **សន ច័ន្ទរិទ្ធី** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- នាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម **គឹម កែវមុនីរ័ត្ន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឧត្តមសេនីយ៍ឯក **ឡោ សុឡេង** | អគ្គស្នងការរងនិងជាស្នងការហិរញ្ញកិច្ចនិងភស្តុភារនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៦- ឧត្តមសេនីយ៍ឯក **ជុន ចារឿត** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. | សមាជិក។ |

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- លើកគម្រោងថវិកាដាក់ជូនប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដើម្បីពិនិត្យសម្រេច និងស្នើសុំរាជរដ្ឋាភិបាលផ្តល់កញ្ចប់ថវិកាសម្រាប់បម្រើឱ្យយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់
- ពិនិត្យលើគម្រោងស្នើសុំរបស់លេខាធិការដ្ឋាន គណៈកម្មការ និងអនុគណៈកម្មការ យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដើម្បីស្នើសុំការសម្រេចពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់



៥៥

- លើកផែនការផ្គត់ផ្គង់ឧបករណ៍ សម្ភារ មធ្យោបាយ ប្រេងឥន្ធនៈ ព្រមទាំងថវិកាសម្រាប់ចំណាយផ្សេងៗ តាមការស្នើសុំឬតាមតម្រូវការជាក់ស្តែងរបស់លេខាធិការដ្ឋាន គណៈកម្មការ និងអនុគណៈកម្មការ យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដើម្បីសុំការសម្រេចពីប្រធានគណៈបញ្ជាការ យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់
- សហការសម្របសម្រួលជួយដល់លេខាធិការដ្ឋានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដើម្បីស្នើសុំថវិកាប្រាក់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំពីរាជរដ្ឋាភិបាលជូនដល់អង្គភាព និងមន្ត្រីអនុវត្ត ច្បាប់ដែលមានស្នាដៃក្នុងការបង្ក្រាប ចាប់យកសារធាតុញៀនដែលមានភាពសុទ្ធចាប់ពី១០០ក្រាម ឡើងទៅ
- ធ្វើការបូកសរុបទូទាត់ចំណាយប្រចាំឆ្នាំក្នុងកិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់តាមនីតិវិធី
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន ខុសច្បាប់។

**ប្រការ១៣ .-**

ប្រធានគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន គណៈកម្មាធិការ អាជ្ញាធរ ក្រុមប្រឹក្សា គណៈកម្មការ និងក្រុមការងារពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ និង/ឬ ចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

**ប្រការ១៤ .-**

គណៈកម្មការនីមួយៗត្រូវរៀបចំឱ្យមានក្រុមការងាររដ្ឋបាល ដើម្បីសម្របសម្រួលការងារជាមួយ លេខាធិការដ្ឋានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

លេខាធិការដ្ឋាននិងគណៈកម្មការនីមួយៗ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទដើម្បីជួយបំពេញការងារ និងមានសិទ្ធិបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់។

**ប្រការ១៥ .-**

គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងគណៈកម្មការនីមួយៗ មានសិទ្ធិ ប្រើរូបសញ្ញានិងត្រារបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

លេខាធិការដ្ឋានមានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន។

**ប្រការ១៦ .-**

ទីតាំងបំពេញការងាររបស់លេខាធិការដ្ឋាន គណៈកម្មការ និងអនុគណៈកម្មការនីមួយៗ ស្ថិតនៅ ក្រសួង ស្ថាប័នរបស់ប្រធានលេខាធិការដ្ឋាន គណៈកម្មការ និងអនុគណៈកម្មការ។

**ប្រការ១៧ .-**

គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ មានថវិកាសម្រាប់ដំណើរការរដ្ឋបាល ដែលត្រូវកំណត់ដោយប្រមុខរាជរដ្ឋាភិបាល។

**ប្រការ១៨ .-**

សេចក្តីសម្រេចលេខ០៨ សសរ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មការចម្រុះ ប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុក ជានិរាករណ៍។

**ប្រការ១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៥ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ